ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ១៣៤៤ អយក.ប្រក

# ប្រកាស
## ស្ដីពី
## ការបើកគ្រឹះស្ថានសិក្សាចំណេះទូទៅឯកជន "សាលាពន្លកខ្មែរ"
## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ ស្ដីពីប្រព័ន្ធអប់រំចំណេះទូទៅ១២ឆ្នាំ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ខែធ្នូឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩២ ស្ដីពីការបើកសាលារៀនចំណេះទូទៅឯកជន
- បានពិនិត្យលិខិតស្នើសុំរបស់លោក **ឃុ សុខខេន** ជានាយកគ្រឹះស្ថានសិក្សា ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៧
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានអប់រំកុមារតូច នាយកដ្ឋានបឋមសិក្សា និងនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

## សម្រេច

**ប្រការ ១.-**

ត្រូវបានអនុញ្ញាតឱ្យបើកគ្រឹះស្ថានសិក្សាចំណេះទូទៅឯកជន "**សាលាពន្លកខ្មែរ**" ចាប់ពីកម្រិតមត្តេយ្យសិក្សា ដល់មធ្យមសិក្សាទុតិយភូមិ ដែលមានទីតាំងស្ថិតនៅក្នុងសង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ចាប់ពីឆ្នាំសិក្សា ២០១៧-២០១៨ នេះតទៅ ។

**ប្រការ ២.-**

គ្រឹះស្ថានសិក្សាចំណេះទូទៅឯកជន **សាលាពន្លកខ្មែរ** ស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និងកីឡា ខេត្តបន្ទាយមានជ័យ និងត្រូវអនុវត្តតាមកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា និងរៀបចំឱ្យសិស្សប្រឡងសញ្ញាបត្រមធ្យមសិក្សាថ្នាក់ជាតិក្នុងសម័យប្រឡងជាមួយគ្រឹះស្ថានមធ្យមសិក្សាសាធារណៈ។

**ប្រការ ៣.-**

គ្រឹះស្ថានសិក្សាចំណេះទូទៅឯកជន **សាលាពន្លកខ្មែរ** ត្រូវមានកម្មវិធីសិក្សាភាសាខ្មែរជាមុខវិជ្ជាគោលនៃកម្មវិធីសិក្សារបស់ខ្លួន។

**ប្រការ ៤.-**

លោក **យូ សុខខេង** ជានាយកគ្រឹះស្ថានសិក្សាត្រូវដឹកនាំ និងគ្រប់គ្រងសាលារៀនទាំងផ្នែករដ្ឋបាល និងផ្នែកបច្ចេកទេស ព្រមទាំងទទួលខុសត្រូវ៖

- ជ្រើសរើសគ្រូបង្រៀនដែលមានសមត្ថភាពគរុកោសល្យ
- ជ្រើសរើសសិស្សឱ្យចូលរៀនដោយមិនមានការរើសអើង
- ធានាដំណើរការបង្រៀន និងរៀនឱ្យប្រកបដោយគុណភាព និងប្រសិទ្ធភាព
- គោរព និងអនុវត្តសារាចរ សេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា
- ធានាសណ្តាប់ធ្នាប់សង្គម និងធានាសុវត្ថិភាពផ្លូវកាយ និងផ្លូវចិត្តចំពោះសិស្សគ្រប់រូប
- ធ្វើរបាយការណ៍រាល់សកម្មភាពសិក្សាផ្នែករដ្ឋបាល និងបច្ចេកទេសជូនមន្ទីរអប់រំ យុវជន និងកីឡា ខេត្តបន្ទាយមានជ័យ និងក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់។

**ប្រការ ៥.-**

ក្រសួងអប់រំ យុវជន និងកីឡា មានសិទ្ធិធ្វើអធិការកិច្ច ត្រួតពិនិត្យតាមដាន និងវាយតម្លៃ ហើយមានសិទ្ធិបិទ ប្រសិនបើគ្រឹះស្ថានសិក្សានេះអនុវត្តខុសពីកិច្ចសន្យាដែលបានចុះជាមួយក្រសួងអប់រំ យុវជន និងកីឡា ។

**ប្រការ ៦.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៧.-**

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ អគ្គាធិការដ្ឋាន នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានអប់រំកុមារតូច នាយកដ្ឋានបឋមសិក្សា នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ អង្គភាពពាក់ព័ន្ធ នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡា ខេត្តបន្ទាយមានជ័យ និងគ្រឹះស្ថានសិក្សាចំណេះទូទៅឯកជន **សាលាពន្លកខ្មែរ** និងសាមីជនមានភារកិច្ចអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៧

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សាលាខេត្តបន្ទាយមានជ័យ

*"ដើម្បីជូនជ្រាបជាព័ត៌មាន"*
- ដូចប្រការ៧

*"ដើម្បីអនុវត្ត"*
- កាលប្បវត្តិ- ឯកសារច្រកចេញចូលតែមួយក្រសួងអប់រំ យុវជន និងកីឡា

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**